# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាប្រសិទ្ធីពរលើព្រះវិហារនៅទួលក្រសាំង
# ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨

*រួមគ្នាកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់*

អត្ថបទទី១៖ កណ ៣,៩-១៥.២០
អត្ថបទទី២៖ អភ ១,៣-៦.១១-១២
ដំណឹងល្អ៖ លក ១,២៦-៣៨

បងប្អូនជាទីស្រឡាញ់!

នៅពេលយើង មើលឃើញព្រះវិហារនៅពេលនេះ ណែនាំឲ្យយើងភ្ញាក់ស្មារតី ពេលមកដល់ទីនេះលើកដំបូងមានទឹកលិចផ្លូវពិបាកប៉ុន្តែថ្ងៃនេះយើងមានព្រះវិហារមួយយ៉ាងធំស្អាត ដើម្បីទទួលស្វាគមន៍បងប្អូនទាំងអស់។ ថ្ងៃនេះខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ សម្រាប់លោកឪពុកទិន លោកឪពុក យង់ គណកម្មការ និងបងប្អូនទាំងអស់ដែលបានរួមគ្នាជួសជុលព្រះវិហារនេះ ដើម្បីឲ្យបងប្អូនមានកន្លែងជួបជុំគ្នាយ៉ាងសមរម្យ។ យើងនឹកឃើញដល់សន្តហ្វ្រង់ស្វ័រ ដែលគាត់បានសុបិនថា គាត់ឃើញវិសាលវិហាររបស់សម្តេចប៉ាបនៅទីក្រុងរ៉ូម ដែលកំពុងដួលហើយសន្តហ្វ្រង់ស្វ័រខិតខំទ្រព្រះវិហារនេះកុំឲ្យដួល ហើយលឺព្រះសូរសៀងថា "**សូមទៅជួលជុលព្រះវិហាររបស់ខ្ញុំ**"។ ក្រោយមកសន្តហ្វ្រង់ស្វ័រ បានទៅព្រះវិហារមួយហើយគាត់បានខិតខំយកចិត្តទុកដាក់ជួសជុលព្រះវិហារនោះ ដូចសន្តហ្វ្រង់ស្វ័របានជួសជុលព្រះវិហារទួលក្រសាំង។ យើងនឹកឃើញដល់ព្រះនាងម៉ារីដែលគ្មានជំពាក់បាប ព្រះនាងម៉ារីដែលបានថ្វាយខ្លួនទៅព្រះជាម្ចាស់ យើងត្រូវការនឹកឃើញអំពីអត្ថន័យនៃព្រះវិហារដែលយើងមាននៅកន្លែងនេះ។ ព្រះវិហារ ជាកន្លែងមួយដើម្បីយើងជួបជុំគ្នា ដើម្បីអធិដ្ឋាន ដើម្បីអរព្រះគុណព្រះជាម្ចាស់ ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីទទួលអគ្គសញ្ញានានា ដែលណែនាំឲ្យយើងមានជីវិត។ ប៉ុន្តែ ជាកន្លែងមួយពិសេស ដើម្បីជួបជាមួយព្រះយេស៊ូ យើងចូលនៅក្នុងរដូវ៤០ថ្ងៃ ថ្ងៃនេះយើងរំលឹកព្រះនាងម៉ារីគ្មានជំពាក់បាប យើងបានស្តាប់អត្ថបទគម្ពីរស្តីអំពី ព្រះនាងម៉ារីទទួលដំណឹងថាធ្វើជាមាតារបស់ព្រះយេស៊ូ។ មានន័យថា ព្រះយេស៊ូចូលនៅក្នុងផ្ទៃពោះព្រះនាងម៉ារី និងព្រះនាងម៉ារីទៅជាព្រះរាជ្យវង្សរបស់ព្រះជាម្ចាស់ ដើម្បីទទួលស្វាគមន៍ព្រះយេស៊ូផ្ទាល់។

ព្រះវិហារមិនមែនជាកន្លែងដែលតុបតែងយ៉ាងស្អាត តែជាព្រះវិហារដ៏មានជីវិត ថ្ងៃនេះយើងសម្លឹងមើលព្រះនាងម៉ារី យើងនឹកឃើញព្រះវិហារដ៏មានជីវិត។ ពេលយើងនឹកឃើញព្រះនាងម៉ារី យើងនឹកឃើញដល់ព្រះវិហារដ៏មានជីវិតដើម្បីទទួលស្វាគមន៍ព្រះយេស៊ូ យើងទាំងអស់យើងទៅជាព្រះវិហារមួយដ៏ពិសេស ដើម្បីទទួលស្វាគមន៍ព្រះយេស៊ូដែលកំពុងយាងមកនៅក្នុងជីវិតរបស់យើង។ "**បងប្អូនយើងមានសុភមង្គលហើយ ដោយសារយើងមានព្រះសហាគមន៍របស់**

**ព្រះគ្រីស្ត សាសងសង់លើក្រុមគ្រីស្តទូត និងព្រះនាងម៉ារីជាព្រះមហាក្សត្រីនៃក្រុមគ្រិស្តទូតទាំងឡាយ**”។ សុភមង្គលនេះត្រូវការឲ្យយើងបន្ត គឺបន្តរស់នៅជាគ្រីស្តបរិស័ទយ៉ាងសកម្ម ទីមួយ ឲ្យយើងទូលអង្វរព្រះជាម្ចាស់ឲ្យយើងមានជំនឿរឹងមាំ។ ទីពីរ ឲ្យយើងមានសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ មានន័យថាសេចក្តីស្រឡាញ់ដ៏ពេញលក្ខណៈយាងចូលនៅក្នុងដួងចិត្តរបស់យើងយ៉ាងពិតប្រាកដ។ ទីបី ឲ្យយើងទៅប្រកាសដំណឹងល្អអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ “**សូមទ្រង់ប្រទានឲ្យគេមានចិត្តសប្បុរស ដើម្បីជួយសម្រាលទុក្ខអ្នកកំសត់ អ្នកស្រេកឃ្លាន អ្នកដែលត្រូវគេសង្កត់សង្កិន និងផ្តល់សេចក្តីសង្ឃឹមដល់អ្នកកំសត់ទុរគត**”។ ឲ្យព្រះសហគមន៍យើងនៅទីនេះ ទៅជាពន្លឺមួយដើម្បីបង្ហាញផ្លូវឲ្យជីវិតរបស់របស់ព្រះយេស៊ូដល់បងប្អូនឯទៀតៗ ដោយធ្វើជាសាក្សីនៃធម៌មេត្តាករុណាជានិច្ច។ ឲ្យទៅជាព្រះវិហាររបស់គ្រីស្តបរិស័ទ ដែលមានចិត្តទូលំទូលាយទទួលស្វាគមន៍បងប្អូនទាំងអស់ ដើម្បីបង្ហាញថាយើងជាមហាគ្រួសារតែមួយ ដែលចេះស្រឡាញ់គ្នា គោរពគ្នា និងជួយគ្នាទៅវិញទៅមកជានិច្ច។ តាមរយៈការសិក្សា យើងបង្កើតទំនាក់ទំនងដើម្បីបង្ហាញថាយើងចាប់អារម្មណ៍អំពីមនុស្សទាំងឡាយ។ តាមរយៈសង្គហៈ យើងយកចិត្តទុកដាក់ជាមួយអ្នកជំងឺ ជាមួយអ្នកក្រីក្រ ដើម្បីឲ្យគេទទួលសេចក្តីសង្ឃឹមនៅក្នុងជីវិតរបស់គេ។ យើងអាចធ្វើទាំងអស់បាន លុះត្រាតែយើងយកចិត្តទុកដាក់អធិដ្ឋាន និងសុំព្រះជាម្ចាស់ប្រទានជីវិតនិងសេចក្តីស្រឡាញ់របស់មនុស្សលោកយើង ដើម្បីទៅជាសាក្សីដែលទទួលកម្លាំងទាំងស្រុងពីព្រះយេស៊ូគ្រីស្តផ្ទាល់។

យើងមានព្រះនាងម៉ារី យើងមានសន្តយ៉ូសែប យើងមានសន្តប្រ៉ាង់ស្វ័រ ដែលជួយការពារយើង ដើម្បីឲ្យយើងទាំងអស់គ្នាធ្វើដំណើរជាមួយព្រះយេស៊ូ កសាងព្រះសហគមន៍ដ៏មានជីវិតរបស់ព្រះគ្រីស្តនៅទីនេះ។ យើងអរព្រះគុណព្រះជាម្ចាស់ តាមរយៈព្រះនាងម៉ារី យើងសន្យាថា យើងទាំងអស់គ្នាយកចិត្តទុកដាក់ទទួលស្វាគមន៍ព្រះយេស៊ូនៅក្នុងខ្លួនយើង ដើម្បីចែករំលែកធម៌មេត្តាករុណារបស់ព្រះអង្គដល់មនុស្សយ៉ាងច្រើន។ អាម៉ែន៕